**ព្រះរាជក្រឹត្យ**

នស/រកត/០២១៧/ ១៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១..**

ត្រូវបានបង្កើត "**គណៈកម្មាធិការជាតិដឹកនាំតម្រង់ទិសការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម**" ដែលមានឈ្មោះជាអក្សរកាត់ "**គ.ជ.ដ.អ**" ដើម្បីសម្របសម្រួលអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦។

**ជំពូកទី ២**

**សមាសភាព**

**មាត្រា ២.-**

**គ.ជ.ជ.អ.** មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកការងារអត្តសញ្ញាណកម្ម | ជាអនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១ រូប ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ | ០១ រូប ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូប ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១ រូប ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ០១ រូប ជាសមាជិក |
| - រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ០១ រូប ជាសមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | ជាសមាជិកអចិន្ត្រៃយ៍ |

ក្រៅពីសមាជិកខាងលើនេះ **គ.ជ.ជ.អ.** អាចស្នើបន្ថែមសមាជិកជារដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធតាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.ជ.ជ.អ.** ត្រូវតែងតាំងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

សមាជិកម្នាក់ៗត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ជ.ជ.អ.**។ ក្នុងករណីមិនអាចចូលរួមប្រជុំបាន សមាជិកនោះអាចចាត់តាំងតំណាងមានសិទ្ធិសម្រេចមួយរូបចូលរួមជំនួសក្នុងកិច្ចប្រជុំ។

**គ.ជ.ជ.អ.** អាចអញ្ជើញតំណាងថ្នាក់រដ្ឋលេខាធិការនៃក្រសួងពាក់ព័ន្ធ ឬប្រធានស្ថាប័នពាក់ព័ន្ធផ្សេងទៀតឱ្យចូលរួមកិច្ចប្រជុំ ការពិភាក្សា ឬសហការការងារតាមការចាំបាច់។

## ជំពូកទី ៣
## តួនាទី ភារកិច្ច របស់ គ.ជ.ជ.អ.

**មាត្រា ៣.-**

**គ.ជ.ជ.អ.** គឺជាយន្តការអន្តរក្រសួងថ្នាក់ជាតិ មានតួនាទីជួយរាជរដ្ឋាភិបាលក្នុងការដឹកនាំសម្របសម្រួល ការចូលរួមសហការ និងការគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ ផ្នែកឯកជន យន្តការក្នុងតំបន់ និងបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយ សម្រាប់ជំរុញនិងអនុវត្តកំណែទម្រង់ប្រព័ន្ធអត្តសញ្ញាណកម្មជាតិ ជាពិសេសការងារអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាន។

**មាត្រា ៤.-**

**គ.ជ.ជ.អ.** មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ជំរុញ និងលើកកម្ពស់ការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាតិនានា និងសន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិកហត្ថលេខី ដែលពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។
- សម្របសម្រួល ដឹកនាំ តម្រង់ទិសការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦។

ROYAUME DU CAMBODGE MINISTRE DU PALAIS

- ផ្តួចផ្តើមគំនិតរៀបចំ និងធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើតបរិយាកាសសមស្របសម្រាប់ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការងារអត្តសញ្ញាណកម្ម ដោយប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។
- ធ្វើសង្គតិភាពការងារកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងការងារអត្តសញ្ញាណកម្ម ជាមួយនឹងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងកំណែទម្រង់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើនប្រសិទ្ធភាពការផ្តល់សេវាអត្តសញ្ញាណកម្មនៅគ្រប់កម្រិត។
- បង្កើតនូវវេទិកាសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់សម្របសម្រួលកិច្ចសហប្រតិបត្តិការ និងគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម។
- ដាក់ចេញនូវគោលការណ៍ណែនាំ និងសេចក្តីសម្រេចនានាតាមការចាំបាច់ លើការងារពាក់ព័ន្ធនឹង អត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។
- ពិគ្រោះយោបល់ និងសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលមានចំណងទាក់ទងកិច្ចការអត្តសញ្ញាណកម្ម ក្នុងការពិនិត្យមើលលើការទទួលខុសត្រូវរបស់ខ្លួនដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាជន។
- ផ្អែកលើផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦ ត្រូវរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ។
- ពិនិត្យលើការបង្កើតមុខងារថ្មីៗ ការកែលម្អមុខងារមួយចំនួន របស់ស្ថាប័នដែលមានការពាក់ព័ន្ធការងារអត្តសញ្ញាណកម្ម និងពិនិត្យសម្រេចលើការអភិវឌ្ឍនិងការប្រើប្រាស់ដំណោះស្រាយដែលផ្អែកលើប្រព័ន្ធគមនាគមន៍និងព័ត៌មាន។
- ធានាបង្កើតឱ្យបាននូវប្រភពព័ត៌មានដ៏មានតម្លៃ និងជឿទុកចិត្តបានអំពីបុគ្គលគ្រប់រូបនៃព្រះរាជាណាចក្រកម្ពុជាដែលអាចបង្កើតបានជាទិន្នន័យប្រជាជនដ៏សុក្រឹត សម្រាប់បម្រើឱ្យវិស័យសាធារណៈនិងវិស័យឯកជន។
- ត្រូវធ្វើការតាមដាននូវវឌ្ឍនភាព និងត្រួតពិនិត្យលើការអនុវត្តការងារជាក់ស្តែង ដើម្បីធានាថាសកម្មភាពទាំងអស់អនុវត្តបានត្រឹមត្រូវដើម្បីកុំឱ្យមានការបរាជ័យ។
- ធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាលទៀងរាល់មួយឆ្នាំម្តង អំពីការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធការងារអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន និងវឌ្ឍនភាព និងបញ្ហាប្រឈមនានាលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦។
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ពីរាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.ជ.អ.

មាត្រា ៥.- គ.ជ.ជ.អ. ត្រូវជួបប្រជុំទៀងរាល់ប្រាំមួយខែម្តង ដើម្បីពិនិត្យមើលឡើងវិញពីសូចនាករសំខាន់ៗដែលទទួលបានពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម និងដោះស្រាយបញ្ហាប្រឈមដែលបានជួបប្រទះ។

ក្នុងករណីចាំបាច់ **គ.ជ.ជ.អ.** អាចប្រជុំវិសាមញ្ញបានតាមការអញ្ជើញរបស់ប្រធាន។ របៀបរបបនៃការប្រជុំរបស់ **គ.ជ.ជ.អ.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ជ.អ.**។

**គ.ជ.ជ.អ.** ត្រូវរៀបចំ និងអនុម័តនូវរបៀបរបបការងារ និងបទបញ្ជាផ្ទៃក្នុង នៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួន។

**មាត្រា ៦..**

**គ.ជ.ជ.អ.** ត្រូវរៀបចំរបាយការណ៍បូកសរុបពីលទ្ធផលសកម្មភាពប្រចាំឆ្នាំ និងលើកអនុសាសន៍នានាដាក់ជូនរាជរដ្ឋាភិបាលនៅរៀងរាល់ចុងឆ្នាំ។

**មាត្រា ៧..**

**គ.ជ.ជ.អ.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍តាមការចាំបាច់។

**មាត្រា ៨..**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មដើរតួនាទីជាលេខាធិការដ្ឋាននៃ **គ.ជ.ជ.អ.**។ លេខាធិការដ្ឋានត្រូវលើកសំណើសុំបង្កើត "**ក្រុមការងារបច្ចេកទេសអនុវត្តកម្មវិធី** ហៅកាត់ថា **ក.ប.អ.ក.**" ដើម្បីជួយដល់លេខាធិការដ្ឋានក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម។

ការរៀបចំនិងការប្រព្រឹត្តទៅនៃ **ក.ប.អ.ក.** ត្រូវកំណត់ដោយ **គ.ជ.ជ.អ.**។

**មាត្រា ៩..**

**គ.ជ.ជ.អ.** ត្រូវប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ។

**មាត្រា ១០..**

**គ.ជ.ជ.អ.** អាចតែងតាំង និងទទួលយកទីប្រឹក្សាបច្ចេកទេសជាតិ អន្តរជាតិមួយចំនួនតាមការចាំបាច់ដើម្បីជួយការងារ **គ.ជ.ជ.អ.** និង **ក.ប.អ.ក.**។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា ១១..**

**គ.ជ.ជ.អ.** ត្រូវរៀបចំផែនការសកម្មភាពនិងថវិកា ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦។

**គ.ជ.ជ.អ.** មានប្រភពធនធានក្នុងកញ្ចប់ថវិការបស់ក្រសួងមហាផ្ទៃ និងអាចទទួលថវិកាពីដៃគូអភិវឌ្ឍន៍អន្តរជាតិផ្សេងៗនានា។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

[illegible]បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ១៣..**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ៕

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ការស. ១៧០២.១៤៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ១៥៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**